# ព្រះរាជក្រឹត្យ

នស/រកត/០៣០៣/១១៥

## ស្តីពី

## ការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ

*****

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

- បានទ្រង់យល់ព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៣

## ទ្រង់ត្រាស់បង្គាប់

### ជំពូកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

កំណត់រមណីយដ្ឋានវប្បធម៌នៃប្រាសាទព្រះវិហារ ជារមណីយដ្ឋានការពារ ស្ថិតនៅលើភ្នំព្រះវិហារនៃជួរភ្នំដងរែក ក្នុងភូមិសាឯម (អតីតភូមិស្វាយជ្រុំ) ឃុំកន្ទួត ស្រុកជាំក្សាន្ត ក្នុងខេត្តព្រះវិហារ ។

**មាត្រា ២.-**

ការបង្កើតរមណីយដ្ឋានការពារនេះមានគោលបំណង :

- អភិរក្សកេរដំណែលវប្បធម៌ ទាំងខាងបុរាណវិទ្យា ជាតិពន្ធុវិទ្យា ប្រវត្តិវិទ្យា និង លើកកិតតំលៃរមណីយដ្ឋានការពារឱ្យកាន់តែប្រសើរថែមទៀត
- អភិរក្ស ទេសភាពវប្បធម៌ និង អភិវឌ្ឍតំបន់ទេសចរណ៍
- ការពារបរិស្ថាន ធម្មជាតិក្នុងតំបន់ តាមភូមិសាស្ត្រជាក់ស្តែង

### ជំពូកទី ២
### ការកំណត់តំបន់

**មាត្រា ៣.-**

តំរូវឱ្យត្រួតពិនិត្យរាល់ការអភិវឌ្ឍរមណីយដ្ឋានការពារ ដោយគោរពតាមប្លង់កំណត់តំបន់ និង ការចាត់ចែងគ្រប់គ្រងតំបន់ តាមចំណាត់ថ្នាក់តំបន់ត្រូវការពារ ។

**មាត្រា ៤.-**

រមណីយដ្ឋានការពារប្រាសាទព្រះវិហារ ត្រូវចាត់ជា ៣ (បី) តំបន់ផ្សេង១គ្នា ហើយត្រូវទទួលកិតការពារខុស១គ្នា :

ក - **តំបន់ទី ១ :** ជាតំបន់រមណីយដ្ឋានប្រាសាទ ហៅថា **តំបន់ស្នូល** កំណត់យកតួភ្នំទាំងមូល

គិតចាប់ពីកំពូលភ្នំ នៃប្រាសាទព្រះវិហារចុះក្រោម រហូតដល់ខ្សែរយៈកំពស់ ៥០០ម៉ែត្រ កំណត់ដោយចំណុច ដែលមានខ្សែរយៈទទឹង និងខ្សែរយៈបណ្តោយដូចតទៅ :

| ចំណុច | រយៈទទឹង | | | រយៈបណ្តោយ | | |
|---|---|---|---|---|---|---|
| 1 | $14^0$ | 23’ | 19” | $104^0$ | 40’ | 54” |
| 2 | 14 | 23 | 27 | 104 | 40 | 46 |
| 3 | 14 | 23 | 37 | 104 | 40 | 35 |
| 4 | 14 | 23 | 30 | 104 | 41 | 14 |
| 5 | 14 | 23 | 42 | 104 | 41 | 21 |
| 6 | 14 | 23 | 59 | 104 | 41 | 31 |
| 7 | 14 | 25 | 15 | 104 | 41 | 04 |
| 8 | 14 | 23 | 48 | 104 | 40 | 37 |
| 9 | 14 | 23 | 53 | 104 | 40 | 43 |

និង ខ្សែបន្ទាត់ព្រំដែនកម្ពុជា - ថៃ ។

តំបន់នេះ ជាតំបន់មានប្រាសាទព្រះវិហារ សំខាន់ជាងគេក្នុងរមណីយដ្ឋានការពារ ហើយត្រូវទទួលកិច្ចការពារកំរិតខ្ពស់បំផុត ។

ខ - **តំបន់ទី ២ :** ជាតំបន់អភិរក្សទេសភាពវប្បធម៌ បរិស្ថានធម្មជាតិ ហៅថា **តំបន់ទ្រនាប់** កំណត់យកផ្ទៃដីចន្លោះបរិវេណនៃតំបន់ស្នូល និង ខ្សែបន្ទាត់ដែលមាន :

- ចំណុចប្រសព្វមុខរវាងខ្សែបន្ទាត់រង្វង់ កាំប្រវែង ៣ គ.ម ចំណុចផ្ចិត E: រយៈទទឹង $14^0$ 23’ 39”; រយៈបណ្តោយ $104^0$ 41’ 02” នៅចំអ័ក្សត្រង់កាំជណ្តើរក្រោមបំផុតនៃប្រាសាទព្រះវិហារ និងខ្សែបន្ទាត់ព្រំដែនកម្ពុជា - ថៃ ហើយនិងអ័ក្សផ្លូវចេញទៅច្រក **តាថាវ** តាមបណ្តោយផ្លូវទៅស្រុកអន្លង់វែងត្រង់ចំណុច :

| ចំណុច | រយៈទទឹង | | | រយៈបណ្តោយ | | |
|---|---|---|---|---|---|---|
| **A** | $14^0$ | 24’ | 22” | $104^0$ | 42’ | 33” |
| **B** | 14 | 22 | 32 | 104 | 42 | 33 |
| **C** | 14 | 22 | 47 | 104 | 39 | 48 |
| **D** | 14 | 23 | 18 | 104 | 40 | 07 |
| **T** | 14 | 23 | 26 | 104 | 41 | 59 |

លើអ័ក្សផ្លូវឡើងទៅចង្កេះភ្នំប្រាសាទព្រះវិហារ រហូតដល់ ខ្សែរយៈកំពស់ ៥០០ម៉ែត្រ ។

តំបន់នេះសំបូរដោយសំណល់បុរាណវត្ថុ ដែលត្រូវការពារ ទប់ស្កាត់នឹងការប្រើប្រាស់ដីធ្លី នឹងការអភិវឌ្ឍមិនសមស្រប ។

គ - **តំបន់ទី ៣ :** ជាតំបន់អភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច និង សង្គមកិច្ច ហៅថា **តំបន់រណប** ដោយរក្សាជីវភាព មុខរបរ អាជីវកម្មតាមទំនៀមទំលាប់ប្រពៃណី ព្រមទាំងការរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់ ។ តំបន់នេះស្ថិតពីខ្សែអ័ក្សខាងក្រៅរបស់តំបន់ទ្រនាប់ចម្ងាយ ១.៥០០ម៉ែត្រ ។

តំបន់នេះជាគោលដៅថែរក្សាបេតិកភ័ណ្ឌវប្បធម៌ និង ធម្មជាតិ តាមរយៈការចាត់ចែងវិធានការដើម្បីជំរុញការអភិវឌ្ឍឱ្យមានចិរភាព និង មានការវាយតំលៃហេតុប៉ះពាល់លើបរិស្ថាន ។

ប្លង់កំណត់តំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ មានក្នុងឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យនេះ ។

## ជំពូកទី ៣

## ការគ្រប់គ្រង ថែទាំ និង ការពារ

**មាត្រា ៥.-**

ការអភិរក្សតំបន់នីមួយៗ សុទ្ធតែត្រូវបានគ្រប់គ្រង ថែទាំ និង ការពារ ស្របតាមទិសដៅចំណាត់ថ្នាក់តំបន់ ដូចមានចែងក្នុងមាត្រា ៤ នៃព្រះរាជក្រឹត្យនេះ និង គិតនៃសារៈសំខាន់ដោយឡែកៗ ខាងបុរាណវិទ្យា ជាតិពន្ធុវិទ្យា ប្រវត្តិវិទ្យា បរិស្ថាន ធម្មជាតិ គោរពសិទ្ធិជាម្ចាស់របស់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ទាំងមូល ខាងជីវភាពរស់នៅ និង លើកស្ទួយរមណីយដ្ឋានការពារឱ្យមានតំលៃកាន់តែខ្ពស់ឡើង ។

**មាត្រា ៦.-**

ត្រូវអនុវត្តនូវនយោបាយរបស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ដើម្បីធានាការគ្រប់គ្រង ថែទាំ និងការពារ ដោយកំណត់ភាពម្ចាស់ការ ទទួលខុសត្រូវរបស់បណ្តាស្ថាប័នមានសមត្ថកិច្ច ដែលមានក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ទទួលអនុវត្តផ្ទាល់ ផ្អែកលើមាត្រា៥ នៃច្បាប់ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ។

បែបបទ និង នីតិវិធី នៃការគ្រប់គ្រង ថែទាំ និង ការពាររមណីយដ្ឋានការពារប្រាសាទព្រះវិហារ ក្នុងបណ្តាមាត្រាខាងលើ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧.-**

បរិវេណ និង រាល់សកម្មភាពរបស់តំបន់នីមួយៗ នៃរមណីយដ្ឋានការពារប្រាសាទព្រះវិហារ អាចពិនិត្យឡើងវិញហើយកែប្រែបាន ដោយផ្អែកលើរាល់លទ្ធផលនៃការស្រាវជ្រាវរបស់អ្នកវិទ្យាសាស្ត្របុរាណវិទ្យា និងស្ថានភាពជាក់ស្តែង ដើម្បីធានាដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គមកិច្ច ការអភិរក្ស និងការគ្រប់គ្រងមួយប្រកបដោយនិរន្តរភាពដូចមានចែងក្នុងមាត្រា ៤ ។

ការកែប្រែតំបន់ និង រាល់សកម្មភាពពាក់ព័ន្ធនឹងរមណីយដ្ឋានប្រាសាទព្រះវិហារ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ តាមសំណើរបស់រាជរដ្ឋាភិបាល ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៩.-**

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១១ខែ មិនា ឆ្នាំ ២០០៣

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

ពរល.០៣.០៣.១២៣ **នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ: ៩៥ ច ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី ១៣ ខែ មិនា ឆ្នាំ២០០៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**[illegible] តាន់**




ផែនទីកំណត់តំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ
ឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យលេខ នស/រកត/០៩០៣/១១៥
ចុះថ្ងៃទី ១១ ខែ ... ឆ្នាំ២០០៣
ស្តីពីការកំណត់តំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ
មាត្រដ្ឋាន 1:50000

សញ្ញាសំគាល់
- ផ្លូវសាងសង់ថ្មី
- ផ្លូវចាស់នៅលើផែនទី
- ++++ ព្រំប្រទល់ប្រទេស
- ខ្សែរយៈកំពស់៥០០ម.
- ខ្សែ៣គ.ម ពីចំណុចកាំទី១ នៃជណ្តើរប្រាសាទ
- ខ្សែព្រំប្រទល់តំបន់ទ្រនាប់

| ចំណុច | រយៈទទឹង | រយៈបណ្ដោយ |
|---|---|---|
| -តំបន់ស្នូល | | |
| 1 | 14°23'19'' | 104°40'54'' |
| 2 | 14 23 27 | 104 40 46 |
| 3 | 14 23 37 | 104 40 35 |
| 4 | 14 23 30 | 104 41 14 |
| 5 | 14 23 42 | 104 41 21 |
| 6 | 14 23 59 | 104 41 31 |
| 7 | 14 25 15 | 104 41 04 |
| 8 | 14 23 48 | 104 40 37 |
| 9 | 14 23 53 | 104 40 43 |
| -តំបន់ទ្រនាប់ | | |
| A | 14 24 22 | 104 42 33 |
| B | 14 22 32 | 104 42 33 |
| C | 14 22 47 | 104 39 48 |
| D | 14 23 18 | 104 40 07 |
| T | 14 23 26 | 104 41 59 |
| -ចំណុចផ្ចិតរង្វង់មានកាំស្មើ៣គ.ម. | | |
| E | 14 23 39 | 104 41 02 |

ប្រភពផែនទី :
.ផែនទី ផងវែក របស់គណៈកម្មការកំណត់ព្រំដែនឥណ្ឌូចិន.សៀម
ខ្នាត ១: ២០០០០០
-ទិន្នន័យវាស់វែងដោយ GPS ឆ្នាំ២០០២
-រូបភាពផ្កាយរណប SPOT ឆ្នាំ១៩៩៩
រៀបចំដោយនាយកដ្ឋានភូមិសាស្ត្រ.១២.២០០២.